# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ សន្និសីទអាស៊ី-ប៉ាស៊ីហ្វិករបស់សមាគមផ្តល់សេវាការងារសាធារណៈពិភពលោក (WAPES) ស្តីពី "ឌីជីថលនីយកម្មក្នុងសេវាការងារសាធារណៈ (Digitalization in Public Employment Services)" រយៈពេលពីរថ្ងៃ គឺនៅថ្ងៃចន្ទ ៦កើត និងថ្ងៃអង្គារ ៧កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២-៣ ខែធ្នូ ឆ្នាំ២០១៩ នៅសណ្ឋាគារ សូហ្វីតែលអង្គរ ភូគីត្រា ខេត្តសៀមរាប។

ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចូលជាសមាជិករបស់ WAPES នៅឆ្នាំ២០១៣ ក្នុងចំណោមសមាជិកចំនួន១២ នៃតំបន់អាស៊ី-ប៉ាស៊ីហ្វិក ហើយត្រូវបានជ្រើសរើសឲ្យធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទអាស៊ី-ប៉ាស៊ីហ្វិកឆ្នាំ២០១៩ ក្រោមកិច្ចសហការជាមួយលេខាធិការដ្ឋានប្រតិបត្តិរបស់ WAPES និងសាធារណរដ្ឋកូរ៉េដែលជាអនុប្រធាន WAPES ទទួលបន្ទុកតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ សន្និសីទនេះ គឺជាបេសកកម្មយ៉ាងសំខាន់មួយរបស់ WAPES ក្នុងគោលបំណងបង្កើតជាវេទិកាសម្រាប់ការដកស្រង់បទពិសោធន៍ ពង្រីកចំណេះដឹង និងផ្តល់ការគាំទ្រដល់រដ្ឋសមាជិកក្នុងការបង្កើនជំនាញថ្មីៗពាក់ព័ន្ធការផ្តល់សេវាការងារសាធារណៈតាមប្រព័ន្ធឌីជីថលឲ្យកាន់តែប្រសើរឡើង។

សន្និសីទនេះ ត្រូវបានរៀបចំឡើងចំពេលវេលា និងក្នុងបរិការណ៍ដែលឌីជីថលនីយកម្មក្នុងការផ្តល់សេវាគ្រប់ប្រភេទកាន់តែមានភាពសកម្មខ្លាំងក្លាឡើង ដែលតម្រូវឲ្យមានការត្រៀមខ្លួន និងស្របយកបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ធ្វើទំនើបកម្មសេវាការងារសាធារណៈនៅកម្ពុជា។ បន្ថែមលើនេះ សន្និសីទនេះក៏ឆ្លើយតបយ៉ាងជាក់ស្តែងទៅនឹងក្របខ័ណ្ឌគោលនយោបាយ និងចក្ខុវិស័យក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ ក្នុងការជំរុញ និងលើកកម្ពស់ការអភិវឌ្ឍវិស័យការងារ ដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ និងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ដែលត្រូវបានរួមបញ្ចូលគ្នានូវដំណោះស្រាយគ្រប់ជ្រុងជ្រោយ សំដៅជំរុញការអភិវឌ្ឍធនធានមនុស្ស ពង្រឹងភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ច រួមទាំងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ដើម្បីបន្តធានាបានកំណើនខ្ពស់ បង្កើតការងារកាន់តែប្រសើរ ពង្រីកកិច្ចគាំពារសង្គមនិងបង្កើនប្រាក់ចំណូលប្រកបដោយស្ថិរភាព និងបរិយាប័ន្ន និងឈានទៅសម្រេចបាននូវក្តីប្រាថ្នាក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។

សន្និសីទនេះក៏ជាវេទិកាផ្តល់នូវកាលានុវត្តភាពក្នុងការចែករំលែកចំណេះដឹង បទពិសោធន៍ និងការអនុវត្តល្អពាក់ព័ន្ធការផ្តល់សេវាការងារសាធារណៈ ក្នុងចំណោមរដ្ឋសមាជិកដែលមានការអភិវឌ្ឍខ្លាំងក្លាផ្នែកការផ្តល់សេវាការងារតាមប្រព័ន្ធឌីជីថល ព្រមទាំងការបង្ហាញពីករណីសិក្សានៃការចាប់ផ្តើមស្របយកបច្ចេកវិទ្យាឌីជីថលចូលក្នុងការផ្តល់សេវាការងាររបស់រដ្ឋសមាជិកថ្មីៗដូចជា ប្រទេសកម្ពុជាជាដើម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងអ្នកសារព័ត៌មានទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ២កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៩